**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១៥៩ . អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការបង្កើតសញ្ញារបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតសញ្ញារបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ សម្រាប់ប្រើប្រាស់ជាផ្លូវការក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

សញ្ញារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចមាននៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចតទៅ ៖

- ទម្រង់ទូទៅជារាងមូល ស្រួចលើ និងស្រួចក្រោម
- ផ្នែកខាងក្រោមបំផុតនៃសញ្ញាមានរូបក្បាច់អង្គុរទ្រសញ្ញាទាំងមូល។ ក្បាច់នេះបញ្ជាក់អំពីប្រជាជាតិមួយប្រកបដោយអរិយធម៌ដ៏រុងរឿង និងសម្បូរបែបដែលតំណាងឲ្យកម្លាំងចលករទ្រទ្រង់វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- រូបស្លឹកស្រូវព័ទ្ធពីខាងក្រៅជារាងស្នែងក្របី ដែលម្ខាងៗមានស្លឹកចំនួន៧ ដោយរួមទាំងស្លឹកសេសមួយនៅខាងលើបំផុត។ រូបស្លឹកស្រូវនេះ តំណាងឲ្យប្រជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ដែលទទួលសេវាពីស្ថាប័នរដ្ឋ លើផ្នែកការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ពាក់កណ្តាលរង្វង់ផ្នែកខាងលើមានអក្សរ "ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ" និងពាក់កណ្តាលរង្វង់ផ្នែកខាងក្រោមដែលខណ្ឌដោយក្បាច់ផ្កាចន្ទន៍តូចៗពីរ មានអក្សរអង់គ្លេស "Ministry of Labour and Vocational Training"។ អក្សរទាំងនេះ ពណ៌ខៀវ ជាឈ្មោះស្ថាប័ន
- រង្វង់ស្តីតំណាងឲ្យគំនិតច្នៃប្រឌិតរស់រវើក និងបង្កើតថ្មីលើការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងបង្កើតការងារដល់ប្រជាពលរដ្ឋគ្រប់ទិសទីប្រកបដោយចីរភាព
- រូបជើងពានពណ៌មាសទ្រសៀវភៅបើកដែលមានចារឹកអក្សរ **ករប** តំណាងឲ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្បួនតម្រាវិជ្ជាសាស្ត្រ អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ និងច្បាប់ស្តីពីការងារ ក៏ដូចជាលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន
- ពណ៌ផ្ទៃមេឃដែលប្រើក្នុងនិម្មិត្តសញ្ញានេះតំណាងឲ្យវឌ្ឍនភាព និងសុខដុមរមនាក្នុងសង្គម។

**មាត្រា៣.-**

សញ្ញារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ប្រើប្រាស់ ដូចខាងក្រោមនេះ ៖

- ដាក់នៅកន្លែងធ្វើការ
- ពាក់លើឯកសណ្ឋានមន្ត្រីរាជការក្នុងក្របខណ្ឌក្រសួង
- ដាក់លើក្បាលលិខិតជាផ្លូវការរបស់ក្រសួង
- ប្រើប្រាស់ជាផ្លូវការផ្សេងៗទៀត។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលនៃគណៈអភិបាលរាជធានី និងខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ [illegible] ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ.....១៩៩.អនក្រ.បក ចុះថ្ងៃទី..២០...ខែ....ធ្នូ.........ឆ្នាំ ២០១០**

**ស្តីពីការបង្កើតសញ្ញារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**